CITY OF LONG BEACH

# ទម្រង់បែបបទទាមទារប្រាក់ - ទឹកប្រាក់មិនទាន់បានទាមទារ

**នាមត្រកូល** **នាមខ្លួន** **M.I.**

**លេខក្រុម # (ដាក់នៅជាប់នឹងឈ្មោះ) ៖**

**លេខអាសយដ្ឋាន និងឈ្មោះផ្លូវ** **Apt/Bldg/Sp #**

**ទីក្រុង** **រដ្ឋ** **លេខកូដតំបន់**

( )

**លេខទូរស័ព្ទ** លេខប័ណ្ណបើកបរ នៅកាលីហ្វ័រញ៉ា ៖

ឈ្មោះអ្នកដាក់ពាក្យទាមទារប្រាក់ ប្រសិនបើខុសពីឈ្មោះខាងលើ ៖

**សូមផ្ញើរ ទម្រង់បែបបទ-ទាមទារប្រាក់ ជូនទៅ ៖**

**Attn: UM Claim**
**Office of The City Treasurer**
**Dept. of Financial Management**
**411 West Ocean Blvd., 6th Floor**
**Long Beach, CA 90802**

- ✓ ពាក្យនេះ **ត្រូវ** ដាក់មក នៅចំ ឬមុន កាលបរិច្ឆេទ មានបញ្ជាក់ នៅក្នុង សេចក្តីជូនដំណឹង ជា សាធារណៈ ថ្មីៗ បំផុត ។
- ✓ សូមបំពេញ ទម្រង់បែបបទ ឱ្យ បានច្បាស់លាស់ & ពេញលេញ ដើម្បីចៀសវាងការពន្យារពេល ។
- ✓ ភ្ជាប់ច្បាប់ចម្លង នៃឯកសារអត្តសញ្ញាណ ។

អនុលោមតាម ក្រមរដ្ឋាភិបាលកាលីហ្វ័រញ៉ា វចក្រខណ្ឌ 50051 អ្នកដាក់ពាក្យទាមទារប្រាក់ ដូចមានចុះហត្ថលេខា ខាងក្រោមនេះ បានផ្តល់ការបញ្ជាក់ ក្រោមបញ្ញត្តិទោសទណ្ឌ ចំពោះការផ្តល់ព័ត៌មានមិនពិត អ្នកដាក់ពាក្យទាមទារប្រាក់ បានអាន ពាក្យទាមទារប្រាក់ បានយល់ដឹង អំពីខ្លឹមសារ ហើយអ្នកដាក់ពាក្យទាមទារប្រាក់ គឺជាម្ចាស់ពាក្យទាមទារប្រាក់ ហើយជាបុគ្គល ដែលមានសិទ្ធិទទួលបាន ទឹកប្រាក់ ចំនួន $____________________ ដូចមានបញ្ជាក់ នៅ ក្នុង ពាក្យទាមទារប្រាក់នេះ ។ អ្នកដាក់ពាក្យទាមទារប្រាក់ គិតថា ខ្លួនជាម្ចាស់ ដោយផ្អែកលើហេតុផល ដែលថា ៖ ______________________________ ។

អាសយដ្ឋានចាស់ របស់អ្នកដាក់ពាក្យសំណើទាមទារប្រាក់ ៖

| | |
|---|---|
| 1. | 2. |
| 3. | 4. |

អ្នកដាក់ពាក្យទាមទារប្រាក់ យល់ព្រម ដាក់ឱ្យ ក្រុងឡុងប៊ិច ព្រមទាំង ភ្នាក់ងារនានា មន្ត្រី និងនិយោជិត របស់ក្រុង រួចផុត ពីការសងសំណង-ខូចខាត និងរួចផុត ពីការខូចខាត ចំពោះការខាតបង់ណាមួយ ដែលកើតចេញពី ការទូទាត់ ទឹកប្រាក់ដែលរងការទាមទារនោះ ។ អ្នកដាក់ពាក្យទាមទារប្រាក់ យល់ដឹងថា ព័ត៌មានបច្ចុប្បន្ន និងហត្ថលេខា ត្រូវមានផ្តល់ សម្រាប់ ពាក្យទាមទារប្រាក់នីមួយៗ បើមិនដូច្នោះទេ ពាក្យទាមទារប្រាក់ នឹងមិនត្រូវដាក់ឆ្លងដំណើរការនោះទេ ។ អ្នកដាក់ ពាក្យ ទាមទារប្រាក់ យល់ដឹងបន្ថែមទៀតថា លេខសន្តិសុខសង្គម លេខអត្តសញ្ញាណពន្ធ ឬឯកសារផ្សេងៗ ទៀត របស់គាត់ ត្រូវបានស្នើ សុំ ដើម្បីធ្វើការកំណត់អត្តសញ្ញាណ និងការដំណើការ លើពាក្យទាមទារប្រាក់ ។ ចំពោះពាក្យទាមទារប្រាក់ ដែល ដាក់មក សម្រាប់ ធុរកិច្ចនោះ ចាំបាច់ត្រូវមាន លេខអត្តសញ្ញាណអ្នកជាប់ពន្ធធុរកិច្ច និងហត្ថលេខា របស់ម្ចាស់ពេញសិទ្ធិ ។ ចំពោះពាក្យទាមទារ ប្រាក់ ដែលដាក់មក សម្រាប់អចលនទ្រព្យ ឬក្រុមធុរកិច្ចនោះ ចាំបាច់ត្រូវមាន ហត្ថលេខាអ្នកតំណាង ពេញសិទ្ធិ ហើយត្រូវភ្ជាប់ ឯកសារសមស្រប ដើម្បីផ្តល់សិទ្ធិដល់ បុគ្គលណាម្នាក់ (ច្រើននាក់) អាចបំពេញការងារ ជំនួស អ្នកដាក់ ពាក្យទាមទារប្រាក់ បាន ។ **ពាក្យទាមទារប្រាក់ ច្រើនជាង $999 នឹងតម្រូវឱ្យមាន ការបញ្ជាក់លើ ហត្ថលេខា របស់ លោកអ្នក ។**

____________________ ឈ្មោះបោះពុម្ព

____________________ កាលបរិច្ឆេទ

____________________ ហត្ថលេខា

____________________ SSN (លេខចុងក្រោយ 4-ខ្ទង់) ឬលេខ TIN

សម្រាប់ការប្រើប្រាស់ របស់សារការី ប្រសិនបើមាន ។

**សម្រាប់ការប្រើប្រាស់ របស់នាយកដ្ឋានហិរញ្ញវត្ថុក្រុង ប៉ុណ្ណោះ**

| **ឯកសារសំអាង សម្រាប់ការផ្ទៀងផ្ទាត់អត្តសញ្ញាណ ៖** (សូមគូសយកគ្រប់ចំណុច ដែលពាក់ព័ន្ធ) | | | |
|---|---|---|---|
| ☐ | **ប័ណ្ណបើកបរ** | ☐ | **ប័ណ្ណសន្តិសុខសង្គម ឬលេខ TIN** |
| ☐ | **សំបុត្រកំណើង** | ☐ | **ផ្សេងៗ ៖** |
| **ផ្ទៀងផ្ទាត់ ដោយ ៖** | | **កាលបរិច្ឆេទ៖** | |
| **អនុម័ត ដោយ ៖** | | **ឯកភាព __________ បដិសេធ __________**<br>**មូលហេតុ នៃការបដិសេធ ៖** | |

CITY OF LONG BEACH

# សេចក្តីណែនាំ អំពីទម្រង់បែបបទសំណើទាមទារប្រាក់

ទីក្រុងឡុងប៊ិច មានភារកិច្ចបញ្ចេញមូលនិធិ ជូនចំពោះ ម្ចាស់មានសិទ្ធិលើប្រាក់ មិន ទាន់ទាមទារ តែប៉ុណ្ណោះ ។ ដើម្បីជួយ ក្រុង ឱ្យដំណើរការលើ ពាក្យទាមទារប្រាក់ របស់លោកអ្នក បាន យើងខ្ញុំសូមស្នើឱ្យលោកអ្នកបំពេញ ទម្រង់បែបបទទាមទារប្រាក់ ហើយដាក់ជូនទៅ ក្រុង ឱ្យបានមុន **កាលបរិច្ឆេទផុតកំណត់ មានកំណត់នៅក្នុង សេចក្តីជូនដំណឹង ជាសាធារណៈ អំពីប្រាក់មិនទាន់បានទាមទារ របស់ ក្រុង ដែលបានផ្សព្វផ្សាយរួច** ។ សេចក្តីណែនាំនេះនឹងជួយលោកអ្នក ក្នុងដំណើរការនោះ ។

| ប្រអប់ | សេចក្តីណែនាំ |
|---|---|
| A | វាយអក្សរ ឬសរសេរ នាមត្រកូល របស់លោកអ្នក ។ |
| B | វាយអក្សរ ឬសរសេរ នាមខ្លួន របស់លោកអ្នក ។ |
| C | វាយអក្សរ ឬសរសេរ អក្សរកាត់ នៃនាមកណ្តាល របស់លោកអ្នក ។ |
| D | វាយអក្សរ ឬសរសេរ លេខកូដ # (អក្សរលេខកូដ ចំនួន 2 តួ នៅបន្ទាប់ ទឹកប្រាក់) |
| E | វាយអក្សរ ឬសរសេរ អាសយដ្ឋានបច្ចុប្បន្ន របស់លោកអ្នក ។ |
| F | វាយអក្សរ ឬសរសេរ ទីក្រុងស្នាក់នៅ របស់លោកអ្នក ។ |
| G | វាយអក្សរ ឬសរសេរ រដ្ឋស្នាក់នៅ របស់លោកអ្នក ។ |
| H | វាយអក្សរ ឬសរសេរ លេខកូដ អាសយដ្ឋាន (zip code) ។ |
| I | វាយអក្សរ ឬសរសេរ លេខទូរស័ព្ទនៅផ្ទះ ឬលេខទូរសព្ទចល័ត របស់លោកអ្នក ។ |
| J | វាយអក្សរ ឬសរសេរ ឈ្មោះបុគ្គល ដែលលោកអ្នក ដាក់ពាក្យទាមទារប្រាក់ ជំនួស ឱ្យ ។ ប្រសិនបើឈ្មោះដូចគ្នា នឹងឈ្មោះខាងលើ មិនបាច់បំពេញនោះទេ ។ |
| K | វាយអក្សរ ឬសរសេរ លេខអាជ្ញាប័ណ្ណបើកបរ នៅកាលីហ្វ័រញ៉ា របស់លោកអ្នក ។ |
| L | វាយអក្សរ ឬសរសេរ ទឹកប្រាក់ ដែលលោកអ្នក ដាក់ពាក្យទាមទារ ។ សូមប្រើ ទម្រង់បែបបទមួយ សម្រាប់ ទឹកប្រាក់ទាមទារ មួយៗ ដាច់គ្នា ។ |
| M | វាយអក្សរ ឬសរសេរ មូលហេតុ ដែលលោកអ្នកគិតថា ទឹកប្រាក់សងមកវិញនោះ ជារបស់លោកអ្នក ។ ឧទាហរណ៍ ៖ ប្រាក់កក់ថ្លៃហ្គាស ប្រាក់កក់ថ្លៃទឹក ឬប្រាក់កក់ សេវាសាធារណៈ ជាទូទៅ ។ ការទូទាត់ប្រាក់លើសចំនួន ចំពោះសំបុត្រចំណត ឬសេវាក្រុងផ្សេងៗ ទៀត ។ |
| N | វាយអក្សរ ឬសរសេរ អាសយដ្ឋានចុងក្រោយ របស់លោកអ្នក ខុសពី អាសយដ្ឋាន បច្ចុប្បន្ន ខាងលើ ។ ប្រសិនបើមានលើសពីមួយ សូមដាក់បញ្ចូល អាសយដ្ឋាន នីមួយៗ បាន រហូតដល់ទៅ បួន (4) អាសយដ្ឋានចាស់ៗ ។ |
| O | វាយអក្សរ ឬសរសេរ ឈ្មោះរបស់លោកអ្នក ។ |
| P | វាយអក្សរ ឬសរសេរ កាលបរិច្ឆេទបច្ចុប្បន្ន ។ |
| Q | ចុះហត្ថលេខា លើទម្រង់បែបបទទាមទារប្រាក់ ។ មានតែ ទម្រង់បែបបទទាមទារ ប្រាក់ច្បាប់ដើម ដែលមានចុះហត្ថលេខា និងឯកសារសំអាង ត្រឹមត្រូវប៉ុណ្ណោះ ដែលនឹងត្រូវយកមក ពិនិត្យមើល និងដាក់ឆ្លងដំណើរការ ។ |
| R | វាយអក្សរ ឬសរសេរ លេខសន្តិសុខសង្គម (លេខចុងក្រោយ -4 ខ្ទង់) ឬលេខអត្ត សញ្ញាណពន្ធ របស់លោកអ្នក ។ |

**កំណត់សម្គាល់ ៖ សម្រាប់ការទាមទារប្រាក់ លើសពីចំនួន $999 នោះ ហត្ថលេខា របស់លោកអ្នក ត្រូវមានការបញ្ជាក់ ពីសារការីសាធារណៈ កាលីហ្វ័រញ៉ា ។**

**អត្តសញ្ញាណ បច្ចុប្បន្ន និងឯកសារសំអាង ត្រឹមត្រូវ របស់ពាក្យទាមទារប្រាក់ ត្រូវមានផ្តល់មក ជាមួយ ឯកសារ ដែលបញ្ជាក់សុពលភាព ដល់ ពាក្យទាមទារប្រាក់ របស់លោកអ្នក ។**

**សូមផ្ញើទម្រង់បែបបទទាមទារប្រាក់ ជូនទៅ ៖**


**ATTN: UM CLAIM**
**OFFICE OF THE CITY TREASURER**
**DEPT OF FINANCIAL MANAGEMENT**
**411 WEST OCEAN BLVD., 6TH FLOOR**
**LONG BEACH, CA 90802**

CITY OF LONG BEACH

# ទម្រង់បែបបទគំរូ - សេចក្តីណែនាំ អំពីទម្រង់បែបបទទាមទារ ប្រាក់

## ទម្រង់បែបបទទាមទារប្រាក់ - ប្រាក់មិនទាន់បានទាមទារ

| (A) នាមត្រកូល | (B) នាមខ្លួន | (C) M.I. |
|---|---|---|

(D) **វខក្រម # (ដាក់នៅជាប់នឹងឈ្មោះ) ៖**

(E) **លេខអាសយដ្ឋាន និងឈ្មោះផ្លូវ** **Apt/Bldg/Sp #**

| (F) ទីក្រុង | (G) រដ្ឋ | (H) លេខកូដតំបន់ |
|---|---|---|

( (I) ) **លេខទូរស័ព្ទ** (K) លេខប័ណ្ណបើកបរ នៅកាលីហ្វ័រញ៉ា ៖

(J) ឈ្មោះអ្នកដាក់ពាក្យទាមទារប្រាក់ ប្រសិនបើខុសពីឈ្មោះខាងលើ ៖

**សូមផ្ញើរ ទម្រង់បែបបទ-ទាមទារប្រាក់ ជូនទៅ ៖**

**Attn: UM Claim**
**Office of The City Treasurer**
**Dept. of Financial Management**
**411 West Ocean Blvd., 6th Floor**
**Long Beach, CA 90802**

- ✓ ពាក្យនេះ **ត្រូវ** ដាក់មក នៅចំ ឬមុន កាលបរិច្ឆេទ មានបញ្ជាក់ នៅក្នុង សេចក្តីជូនដំណឹង ជា សាធារណៈ ថ្មីៗ បំផុត ។
- ✓ សូមបំពេញ ទម្រង់បែបបទ ឱ្យ បានច្បាស់លាស់ & ពេញលេញ ដើម្បីចៀសវាងការពន្យារពេល ។
- ✓ ភ្ជាប់ច្បាប់ចម្លង នៃឯកសារអត្តសញ្ញាណ ។

អនុលោមតាម ក្រមរដ្ឋាភិបាលកាលីហ្វ័រញ៉ា វចក្រខណ្ឌ 50051 អ្នកដាក់ពាក្យទាមទារប្រាក់ ដូចមានចុះហត្ថ លេខា ខាងក្រោមនេះ បានផ្តល់ការបញ្ជាក់ ក្រោមបញ្ញត្តិទោសទណ្ឌ ចំពោះការផ្តល់ព័ត៌មានមិនពិត អ្នកដាក់ពាក្យ ទាមទារប្រាក់ បានអាន ពាក្យទាមទារប្រាក់ បានយល់ដឹង អំពីខ្លឹមសារ ហើយអ្នកដាក់ពាក្យទាមទារប្រាក់ គឺជាម្ចាស់ ពាក្យទាមទារប្រាក់ ហើយជាបុគ្គល ដែលមានសិទ្ធិទទួលបាន ទឹកប្រាក់ ចំនួន $ (L) ____________ ដូចមានបញ្ជាក់ នៅក្នុង ពាក្យទាមទារប្រាក់នេះ ។ អ្នកដាក់ពាក្យទាមទារប្រាក់ គិតថា ខ្លួនជាម្ចាស់ ដោយផ្អែកលើហេតុ ផល ដែលថា ៖ (M) ____________ ។

អាសយដ្ឋានចាស់ របស់អ្នកដាក់ពាក្យទាមទារប្រាក់ ៖

| | |
|---|---|
| 1. (N) | 2. (N) |
| 3. (N) | 4. (N) |

អ្នកដាក់ពាក្យទាមទារប្រាក់ យល់ព្រម ដាក់ឱ្យ ក្រុងឡុងប៊ិច ព្រមទាំង ភ្នាក់ងារនានា មន្ត្រី និងនិយោជិត របស់ក្រុង រួចផុត ពីការសងសំណង-ខូចខាត និងរួចផុត ពីការខូចខាត ចំពោះការខាតបង់ណាមួយ ដែលកើតចេញពី ការទូទាត់ ទឹកប្រាក់ដែលរងការទាមទារនោះ ។ អ្នកដាក់ពាក្យទាមទារប្រាក់ យល់ដឹងថា ព័ត៌មានបច្ចុប្បន្ន និងហត្ថលេខា ត្រូវមានផ្តល់ សម្រាប់ ពាក្យទាមទារប្រាក់នីមួយៗ បើមិនដូច្នោះទេ ពាក្យទាមទារប្រាក់ នឹងមិនត្រូវដាក់ឆ្លងដំណើរការនោះទេ ។ អ្នកដាក់ ពាក្យ ទាមទារប្រាក់ យល់ដឹងបន្ថែមទៀតថា លេខសន្តិសុខសង្គម លេខអត្តសញ្ញាណពន្ធ ឬឯកសារផ្សេងៗ ទៀត របស់គាត់ ត្រូវបានស្នើ សុំ ដើម្បីធ្វើការកំណត់អត្តសញ្ញាណ និងការដំណើការ លើពាក្យទាមទារប្រាក់ ។ ចំពោះពាក្យទាមទារប្រាក់ ដែល ដាក់មក សម្រាប់ ធុរកិច្ចនោះ ចាំបាច់ត្រូវមាន លេខអត្តសញ្ញាណអ្នកជាប់ពន្ធធុរកិច្ច និងហត្ថលេខា របស់ម្ចាស់ពេញសិទ្ធិ ។ ចំពោះពាក្យទាមទារ ប្រាក់ ដែលដាក់មក សម្រាប់អចលនទ្រព្យ ឬក្រុមធុរកិច្ចនោះ ចាំបាច់ត្រូវមាន ហត្ថលេខាអ្នកតំណាង ពេញសិទ្ធិ ហើយត្រូវភ្ជាប់ ឯកសារសមស្រប ដើម្បីផ្តល់សិទ្ធិដល់ បុគ្គលណាម្នាក់ (ច្រើននាក់) អាចបំពេញការងារ ជំនួស អ្នកដាក់ ពាក្យទាមទារប្រាក់ បាន ។ **ពាក្យទាមទារប្រាក់ ច្រើនជាង $999 នឹងតម្រូវឱ្យមាន ការបញ្ជាក់លើ ហត្ថលេខា របស់ លោកអ្នក ។**

(O) ____________ ឈ្មោះបោះពុម្ព

(P) ____________ កាលបរិច្ឆេទ

(Q) ____________ ហត្ថលេខា

(R) ____________ SSN (លេខចុងក្រោយ 4-ខ្ទង់) ឬលេខ TIN

សម្រាប់ការប្រើប្រាស់ របស់សារការី ប្រសិនបើមាន ។

---

**សម្រាប់ការប្រើប្រាស់ របស់នាយកដ្ឋានហិរញ្ញវត្ថុក្រុង ប៉ុណ្ណោះ**

**ារសំអាង សម្រាប់ការផ្ទៀងផ្ទាត់អត្តសញ្ញាណ ៖** (សូមគូសយកគ្រប់ចំណុច ដែលពាក់ព័ន្ធ)

| | | | |
|---|---|---|---|
| ☐ | **ប័ណ្ណបើកបរ** | ☐ | **ប័ណ្ណសន្តិសុខសង្គម ឬលេខ TIN** |
| ☐ | **សំបុត្រកំណើង** | ☐ | **ផ្សេងៗ ៖** |
| **ផ្ទៀងផ្ទាត់ ដោយ ៖** | | **កាលបរិច្ឆេទ៖** | |
| **អនុម័ត ដោយ ៖** | | **ឯកភាព** ____________ **បដិសេធ** ____________ <br> **មូលហេតុ នៃការបដិសេធ ៖** | |

CITY OF
LONGBEACH

# ប្រាក់មិនទាន់បានទាមទារ - សំណួរ និងចម្លើយ

1. **តើខ្ញុំត្រូវទៅទីណាដើម្បីរកមើលថា ខ្ញុំមានទឹកប្រាក់ដែលមិនទាន់បានទាមទារដែលបង្កក់ទុកដោយ ក្រុងសម្រាប់ខ្ញុំ ?**
   A: សូមចូលទៅ គេហទំព័រទីក្រុងឡុងប៊ិច ហើយចុចលើ ដំណរ ដែលមានចំណងជើងថា “ទឹក ប្រាក់ដែលមិនទាន់បានទាមទារ (Unclaimed Money)” ។ សូមធ្វើតាម សេចក្តីណែនាំ ។
2. **ប្រសិនបើខ្ញុំឃើញមានឈ្មោះខ្ញុំនៅក្នុងបញ្ជី តើ ខ្ញុំត្រូវធ្វើអ្វី បន្ទាប់ទៀត?**
   A: សូមបំពេញ ហើយបញ្ជូន ទម្រង់បែបបទទាមទារប្រាក់ និងភ្ជាប់មកជាមួយនូវច្បាប់ចម្លង នៃឯកសារដែលមានស្នើសុំឱ្យដាក់ ។
3. **តើខ្ញុំទៅយក ទម្រង់បែបបទទាមទារប្រាក់ នៅឯណា ?**
   A: សូមបោះពុម្ព ទម្រង់បែបបទទាមទារប្រាក់ និងសេចក្តីណែនាំ ស្តីពីការដាក់ពាក្យ ពីគេ ហទំព័រ ស្តីពីទឹកប្រាក់ដែលមិនទាន់បានទាមទារ (Unclaimed Money website) ។
4. **តើមានកាលបរិច្ឆេទកំណត់ សម្រាប់ការដាក់ ពាក្យទាមទារប្រាក់ របស់ខ្ញុំ ដែរឬទេ ?**
   A: ពាក្យទាមទារប្រាក់ត្រូវយកមកដាក់ក្នុងរយៈពេល 45 ថ្ងៃចាប់ពីពេលមាន សេចក្តី-ជូន ដំណឹង ជាសាធារណៈ ។ សូមមើល គេហទំព័រ ស្តីពីទឹកប្រាក់ ដែលមិនទាន់បានទាមទារ សម្រាប់កាលបរិច្ឆេទពិតប្រាកដ ។
5. **តើខ្ញុំអាចដាក់ ទម្រង់បែបបទទាមទារប្រាក់ នៅការិយាល័យក្រុងណាមួយបានដែរឬទេ ?**
   A: មិនបានទេ ។ ពាក្យបណ្តឹងទាមទារសំណងត្រូវតែផ្ញើទៅការិយាល័យរបស់ហេរញ្ញិកស៊ីធីនៅជាន់ទី ៦ សាលាក្រុងមានទីតាំងនៅ 411 West Ocean Blvd., ទីក្រុងឡុងប៊ិច, រដ្ឋកាលីហ្វ័រញ៉ា 90802 ។
6. **តើហេតុអ្វី បានជាខ្ញុំត្រូវផ្តល់ អសយដ្ឋានចាស់ៗ និងលេខសន្តិសុខសង្គម ឬ** លេខ **TIN របស់ខ្ញុំ ?**
   A: ដើម្បីកំណត់អត្តសញ្ញាណលោកអ្នក ជាម្ចាស់ពេញសិទ្ធិ ក្រុងត្រូវការព័ត៌មាន ដែលយើងអាច ប្រើប្រាស់បាន ដើម្បីបញ្ជាក់ចេញពីកំណត់ត្រារបស់យើង ។ លេខសន្តិសុខសង្គម ឬ TIN របស់ លោកអ្នកមិនត្រូវបានបង្ហាញឱ្យគេដឹងនោះទេ ។
7. **តើត្រូវចំណាយពេលប៉ុន្មាន ដើម្បីដំណើរការពាក្យទាមទារប្រាក់ ?**
   A: មានរយៈពេល ប្រមាណ 90 ថ្ងៃ គិតពីកាលបរិច្ឆេទ ដែលមន្ត្រីគ្រប់គ្រងរតនាគារក្រុង បាន ទទួលពាក្យនោះ ។
8. **តើខ្ញុំអាចដាក់ពាក្យស្នើសុំទាមទារប្រាក់សម្រាប់អ្នកផ្សេង ដែលមិនមែនជាសាច់ញាតិបានដែរឬទេ ?**
   A: បាន តែក្រោមលក្ខខណ្ឌមួយចំនួន ។ ប្រសិនបើលោកអ្នកជាអ្នកគ្រប់គ្រង ឬអ្នកប្រតិបត្តិ នៃអចលនទ្រព្យរបស់បុគ្គល ទទួលមរណភាព លោកអ្នកអាចដាក់ពាក្យទាមទារប្រាក់ តាំង នាមឱ្យអ្នកទាមទារប្រាក់បាន ។ លោកអ្នកត្រូវផ្តល់ភស្តុតាងនៃសិទ្ធិស្របច្បាប់របស់លោក អ្នកក្នុងការដាក់ពាក្យទាមទារប្រាក់សម្រាប់បុគ្គលនោះ ។
9. **តើខ្ញុំអាចដាក់ពាក្យទាមទារប្រាក់ សម្រាប់សាច់ញាតិ បានដែរឬទេ ?**
   A: បាន ប្រសិនបើសាច់ញាតិគឺជាជនក្នុងបន្ទុកឬលោកអ្នកមានសិទ្ធិស្របច្បាប់ក្នុងការតំណាង ឱ្យសាច់ញាតិនោះ ។ លោកអ្នកត្រូវផ្តល់ភស្តុតាងនៃសិទ្ធិស្របច្បាប់របស់លោកអ្នកក្នុងការ ដាក់ ពាក្យទាមទារប្រាក់ សម្រាប់បុគ្គលនោះ ។
10. **តើខ្ញុំអាចដាក់ ពាក្យទាមទារប្រាក់ សម្រាប់ធុរកិច្ច បានដែរឬទេ ?**
   A: បាន ប្រសិនបើលោកអ្នកជាម្ចាស់ស្របច្បាប់នៃធុរកិច្ចនោះឬមានសិទ្ធិតំណាងឱ្យធុរកិច្ច នោះ ។ លោកអ្នកត្រូវផ្តល់ភស្តុតាង នៃសិទ្ធិស្របច្បាប់នោះ ។
11. **តើខ្ញុំអាចដាក់ ពាក្យទាមទារប្រាក់ សម្រាប់ស្វាមី-ភរិយាខ្ញុំ បានដែរឬទេ ?**
   A: មិនបានទេ លើកលែងករណីដែលលោកអ្នកមានសិទ្ធិស្របច្បាប់ក្នុងការតំណាងឱ្យគាត់។ លោកអ្នកត្រូវផ្តល់ភស្តុតាងនៃសិទ្ធិស្របច្បាប់របស់លោកអ្នកក្នុងការដាក់ពាក្យទាមទារប្រាក់ សម្រាប់បុគ្គលនោះ ។
12. **តើខ្ញុំនឹងទទួលបានដំណឹង ដែរឬទេ ប្រសិនបើពាក្យទាមទារប្រាក់ របស់ខ្ញុំ ទទួលបានការឯកភាព ?**
   A: មិនបានទេ ។ ជាទូទៅ ប្រសិនបើពាក្យទាមទារប្រាក់ ត្រូវបានឯកភាព នោះ អ្នកដាក់ពាក្យ នឹង ទទួលបានទឹកប្រាក់សំណង ក្នុងរយៈពេល 90 ថ្ងៃ ។ សេចក្តីជូនដំណឹង នឹងត្រូវចេញជូន សម្រាប់តែ ពាក្យទាមទារប្រាក់ណាដែលត្រូវបានបដិសេធប៉ុណ្ណោះ ។
13. **ចុះបើពាក្យទាមទារប្រាក់ របស់ខ្ញុំ ត្រូវបានបដិសេធវិញ ?**
   A: ប្រសិនបើពាក្យទាមទារប្រាក់របស់លោកអ្នកត្រូវបានបដិសេធលោកអ្នកនឹងទទួលបាន លិខិតមួយច្បាប់ដែលពន្យល់ពីមូលហេតុនៃការបដិសេធនោះ និងជំហានបន្ទាប់ ត្រូវធ្វើ ដើម្បីបន្តពាក្យទាមទារប្រាក់ របស់លោកអ្នក ។
14. **តើវានឹងត្រូវការពេលវេលាយូរជាធម្មតា ដើម្បីទទួលបានការទូទាត់នូវទឹកប្រាក់ ដែលទាមទារ ក្នុងចំនួនច្រើនដែរឬទេ ?**
   A: ជាទូទៅ មិនដូច្នេះទេ ។ ពាក្យទាមទារប្រាក់ ក្នុងចំនួនច្រើន ត្រូវបានដំណើរការ ដូចគ្នា នឹង ពាក្យទាមទារប្រាក់ផ្សេងទៀត ផងដែរ ដោយមានការលើកលែងថា ពាក្យទាមទារប្រាក់ ដែលមានចំនួនលើស $999.00 តម្រូវឱ្យអ្នកដាក់ពាក្យ ធ្វើការបញ្ជាក់លើ ទម្រង់បែបបទ ទាមទារប្រាក់ ។